# មេរៀនទី ១៥៦៖ យ៉ូបនៅតែស្មោះត្រង់នៅក្នុងពេលវេទនាលំបាក

យ៉ូប ១៖១-២៖១០; ៤២៖១-៦,១០-១៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/R3Agd8Fx0q0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/PtWuIDTimdU

**គោលបំណង៖ ព្រះគង់ជាមួយយើងនៅពេលយើងជួបទុក្ខលំបាក។**

**ខគម្ពីរចងចាំ៖ ចោទិយកថា ៣១៖៦** *"ដូច្នេះចូរមានកំឡាំងហើយចិត្តក្លាហានឡើង កុំឲ្យខ្លាចឬមានសេចក្ដីភ័យញ័រចំពោះគេឡើយ ដ្បិតគឺព្រះយេហូវ៉ាជាព្រះនៃឯង ដែលយាងទៅជាមួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោសឯងទេ ក៏មិនដែលលះចោលឯងដែរ។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

២. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

៣. ចូរមានកម្លាំងនិងមានចិត្តក្លាហានចុះ https://youtu.be/Mr7oyUvG7U8

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«បាល់លើទឹក»**





សម្ភារៈដែលត្រូវការ៖ កែវជ័រ កូនបាល់

១. ចែកកុមារជាពីក្រុម

២. ដាក់កែវ ៣ និងដាក់ទឹកឲ្យពេញកែវនោះ ហើយដាក់កែវនោះជាជួរជាប់ៗគ្នា។

៣. ដាក់កូនបាល់ នៅក្នុងកែវទី១ ហើយឲ្យកុមារទី១មកពីក្រុមទាំងពីរ ព្យាយាមផ្លុំបាល់នោះឲ្យទៅឲ្យដល់ កែវទី ៣ ដោយមិនឲ្យបាល់នោះធ្លាក់នោះទេ។

៤. ក្រុមណាដែលអាចផ្លុំបាល់នោះទៅដល់កែវទី៣ បានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា នៅពេលដែលមានការអ្វីមួយដែលមើលទៅហាក់បីដូចជាពិបាក យើងត្រូវតែអត់ធ្មត់ និងមិនត្រូវចុះចាញ់នោះទេ ព្រះគឺតែងតែគង់នៅជាមួយយើងជានិច្ច។

**៤. ការណែនាំមេរៀន**

តើអ្នកធ្លាប់ឈឺចាប់ហើយមានអារម្មណ៍ថាគ្មានអ្នកខ្វល់ខ្វាយពីអ្នកដែរឬទេ? ប្រហែលជាអ្នកអាចនឹងយំ ប៉ុន្តែវាហាក់ដូចជាគ្មាននរណានៅទីនោះដើម្បីជួយលួងអ្នកទេ។ មានបុរសម្នាក់នៅក្នុងព្រះគម្ពីរដែលបានឆ្លងកាត់រឿងដ៏លំបាកក្រៃលែង ហើយសាតាំងព្យាយាមធ្វើយ៉ាងណាឱ្យបុរសម្នាក់នោះបន្ទោសព្រះ ដែលធ្វើឱ្យគាត់រងទុក្ខលំបាកបែបនេះ។ តើអ្នកគិតថាបុរសម្នាក់នោះនឹងបន្ទោសព្រះដែរឬទេ? តោះ! សូមឱ្យយើងរៀនជាមួយគ្នាពីសាច់រឿងមួយនេះ!

**៥. រឿងនៅក្នុងព្រះគម្ពីរ**

រឿងនៅក្នុងព្រះគម្ពីរនៅថ្ងៃនេះគឺនិយាយពីបុរសម្នាក់ឈ្មោះយ៉ូប។ យ៉ូបគឺជាបុរសដ៏ល្អម្នាក់។ គាត់ស្រឡាញ់ព្រះណាស់។ ព្រះបានប្រទានពរឱ្យយ៉ូបមានកូនប្រុសចំនួន ៧ និង កូនស្រី ៣ នាក់។ ព្រះក៏បានប្រទានពរឱ្យយ៉ូបមានហ្វូងសត្វជាច្រើនដែលធ្វើឱ្យគាត់ក្លាយជាអ្នកមានម្នាក់។ យ៉ូបស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្តរបស់គាត់ ប៉ុន្តែមានមនុស្សមួយចំនួនបានគិតថាយ៉ូបស្រឡាញ់ព្រះគឺដោយសារតែទ្រង់ប្រទានពរដល់

គាត់តែប៉ុណ្ណោះ។ ពួកគេច្បាស់ក្នុងចិត្តថាយ៉ូបនឹងបែរចេញពីព្រះវិញបើសិនជាគាត់បាត់បង់នូវព្រះពរទាំងអស់នោះ។

ថ្ងៃមួយមានរឿងដ៏អាក្រក់មួយបានកើតឡើងចំពោះយ៉ូប។ ដោយកូនប្រុសស្រី និង ហ្វូងសត្វរបស់គាត់ទាំងអស់បានស្លាប់! ផ្ទះរបស់គាត់ត្រូវបានឆេះ ហើយយ៉ូបផ្ទាល់ក៏មានជម្ងឺជាទម្ងន់ថែមទៀត។ រឿងនេះធ្វើឱ្យគាត់ពិបាកចិត្តយ៉ាងខ្លាំង ហើយគាត់ក៏ចាប់ផ្ដើមឆ្ងល់ថាហេតុអ្វីបានជារឿងទាំងនេះកើតឡើងចំពោះគាត់។ ប៉ុន្តែការនេះមិនបានធ្វើឱ្យគាត់បែរចេញពីព្រះនោះឡើយ។

បន្ទាប់មកមានមិត្តភក្តិរបស់គាត់បានមកនិយាយលួងលោមគាត់។ ប៉ុន្តែជំនួសឱ្យការនិយាយលួងលោមយ៉ូប មិត្តភក្តិរបស់គាត់ទាំងប៉ុន្មាននាក់នោះបាននិយាយថា យ៉ូបជួបរឿងឈឺចាប់ទាំងនេះ គឺដោយព្រោះតែគាត់បានធ្វើអ្វីខុសហើយ ទើបធ្វើឱ្យគាត់ទៅជាយ៉ាងនេះ។ យ៉ូបបានប្រកែកថាគាត់មិនបានធ្វើអ្វីខុសនោះទេ។

ពេលខ្លះ មនុស្សតែងនិយាយថាពេលដែលមានរឿងអាក្រក់កើតឡើងគឺដោយសារព្រះកំពុងតែដាក់ទោសហើយ។ នេះមិនមែនជាការពិតនោះទេ។ ព្រះជាម្ចាស់មិនដែលចង់ដាក់ទោសយើងឡើយ។ ព្រះទ្រង់ស្រឡាញ់យើងរាល់គ្នា។ យើងរងទុក្ខលំបាកដោយព្រោះតែកំហុសរបស់យើង ឬពីព្រោះកំហុសរបស់មនុស្សដទៃ។ ហើយព្រះតែងតែគង់ជាមួយយើងនៅពេលដែលយើងរងទុក្ខលំបាក។ យើងអាចនឹងមើលមិនឃើញព្រះដែលទ្រង់គង់ជាមួយយើងនៅពេលដែលយើងឆ្លងកាត់ការលំបាក ដែលធ្វើឱ្យយើងគិតថាយើងកំពុងតែនៅម្នាក់ឯង។

ប៉ុន្តែយ៉ូបដឹងថាព្រះជាម្ចាស់គង់នៅជាមួយគាត់គ្រប់ពេល។ យ៉ូបបាននិយាយថា គាត់នៅតែស្រឡាញ់ដល់ព្រះជាម្ចាស់ ហើយគាត់នៅតែបន្តសរសើរតម្កើងទ្រង់ជារៀងរហូត។ ហើយវាជាការពិតមែន នៅពេលដែលយ៉ូបបានស្រឡាញ់ដល់ព្រះជាម្ចាស់ទាំងដែលគាត់ជួបទុក្ខលំបាក ព្រះបានប្រទានពរដល់គាត់មានកូនចំនួន ១០ នាក់ និងហ្វូងសត្វជាច្រើនលើសមុនទៅទៀត។ យ៉ូបពិតជារីករាយណាស់ដែលគាត់បានទុកចិត្តថាព្រះពិតជាគង់នៅជាមួយគាត់នៅពេលដែលគាត់រងទុក្ខលំបាក។

ព្រះទ្រង់គង់ជាមួយយើងទោះបីជាយើងមើលមិនឃើញទ្រង់ក៏ដោយ។ ព្រះអង្គបានសន្យាថាទ្រង់នឹងមិនចាកចេញឬបំភ្លេចយើងចោលនោះឡើយ។ ហើយនៅពេលដែលអ្នកជួបទុក្ខលំបាក ឬ ឃើញអ្នកដទៃជួបនូវការលំបាក សូមចាំថាព្រះជាម្ចាស់ទ្រង់គង់ជាមួយយើងនៅពេលយើងជួបរឿងឈឺចាប់។

## ៦. សំនួរពិភាក្សា

១. តើរឿងអាក្រក់អ្វីខ្លះបានកើតឡើងចំពោះយ៉ូប? *(កូនរបស់គាត់បានស្លាប់, សត្វរបស់គាត់ទាំងអស់ងាប់, ផ្ទះត្រូវភ្លើងឆេះ, ហើយគាត់ធ្លាក់ខ្លួនឈឺ)*

២. តើមនុស្សមួយចំនួនចង់ឱ្យយ៉ូបធ្វើអ្វីនៅពេលដែលគាត់ជួបរឿងដ៏លំបាកទាំងនោះ? *( ចង់ឱ្យគាត់បែរចេញពីព្រះ)*

៣. តើយ៉ូបបានធ្វើអ្វីនៅពេលគាត់កំពុងជួបរឿងឈឺចាប់? *(គាត់ស្រឡាញ់ និង ទុកចិត្តព្រះ)*

៤. តើអ្វីដែលធ្វើឱ្យអ្នកឈឺចាប់នៅថ្ងៃនេះ ហើយតើព្រះអាចជួយអ្នកអ្វីខ្លះ? *(សូមឱ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ចំនួនលេខ»




សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាស លេខ ៣ ឈុត (ពីលេខ ១ ដល់លេខ ៩)

១. ចែកកុមារជា ៣ក្រុម ហើយឲ្យលេខ ១ឈុតទៅក្រុមនីមួយៗ(លេខ ១ ដល់លេខ ៩)

២. នៅពេលដែលគ្រូហៅលេខណាមួយ សមាជិកក្រុមនីមួយៗត្រូវតែព្យាយាមជួយគ្នារៀបលេខនោះឲ្យត្រូវតាមគ្រូនិយាយ។ ឧទាហរណ៍៖ ប្រសិនបើគ្រូហៅលេខ “១៩៣៧” ឬ “២៥៨៣” ឬក៏ “៩៧២” នោះកុមារត្រូវរៀបលេខនោះឲ្យត្រូវតាមលំ ដាប់លំដោយ។ ពេលដែលពួកគេរួចរាល់ គេត្រូវលើកដៃឡើង។

៣. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា វាប្រហែលជាមិនងាយស្រួលទេក្នុងការលេងល្បែងនេះ។ ប្រហែលជាមាន រឿងក្នុងជីវិតដែលមិនងាយស្រួល។ ប៉ុន្តែត្រូវចាំជានិច្ចថា ព្រះគង់នៅជាមួយយើងពេលយើងឈឺចាប់ ឬពេលយើងឆ្លងកាត់គ្រាលំបាក។

### ៨. ខគម្ពីរចេចាំ

**ចោទិយកថា ៣១:៦** “ដូច្នេះចូរមានកំឡាំងហើយចិត្តក្លាហានឡើង កុំឲ្យខ្លាចឬមានសេចក្តីភ័យញ៉័រចំពោះគេឡើយ ដ្បិតគឺព្រះយេហូវ៉ាជាព្រះនៃឯង ដែលយាងទៅជាមួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោស ឯងទេ ក៏មិនដែលលះចោលឯងដែរ។”

### ៩. ហត្ថកម្ម «តំណក់ទឹកភ្នែកប្រែទៅជាបេះដូង»

សំភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសហត្ថកម្ម, កូល័រទៀន, កន្ត្រៃ



១. ចែកក្រដាសហត្ថកម្មដល់កុមារម្នាក់មួយ និងឱ្យពួកគេផាត់ពណ៌រូបតំណក់ទឹកភ្នែក

២. សូមបត់ក្រដាសតាមបន្ទាត់ដាច់ៗ ហើយកាត់រូប តំណក់ ទឹកភ្នែកនោះ។ សូមកុំកាត់គែមនៃបន្ទាត់ដាច់នោះ។



៣. សូមបើករូបតំណក់ទឹកភ្នែកដែលបានកាត់ហើយនោះ ហើយដាក់ផ្កាប់ ចុះក្រោម នោះអ្នកនឹងឃើញចេញជារូបបេះដូងដែលមានរូបញ ញឹមនៅលើនោះ

សូមពន្យល់កុមារថា ព្រះជាម្ចាស់ទ្រង់គង់ជាមួយយើងនៅពេលយើងកើតទុក្ខ។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

មនុស្សគ្រប់គ្នាតែងជួបនូវរឿងឈឺចាប់។ នៅក្នុងការលូតលាស់នៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះយេស៊ូវ យើងជួបរឿងលំបាកផ្សេងពីគ្នា ពីព្រោះព្រះទ្រង់នាំយកនូវសេចក្តីសង្ឃឹមទៅចំពោះអ្នកដែលឈឺចាប់។ យ៉ូប ៤២:១-៦បានប្រាប់យើងថា យ៉ូបបានមានបទពិសោធន៍ជាមួយព្រះកាន់តែខ្លាំងឡើងហើយគាត់បានឆ្លើយតបទៅកាន់ព្រះដោយការថ្វាយបង្គំ។ ក្នុងសប្តាហ៍នេះ សូមរកនូវអ្វីដែលធ្វើឱ្យអ្នកឈឺចាប់នៅក្នុងជីវិត។ ហើយធ្វើការឆ្លុះបញ្ចាំងទៅលើអ្វីដែលអ្នកបាត់បង់ និង អន់ចិត្ត ហើយទូលសូមដល់ព្រះបានប្រើនូវការបាត់បង់ និង បាក់ទឹកចិត្តទាំងនោះដើម្បីឱ្យយើងបានឃើញពីទ្រង់កាន់តែច្បាស់ គឺដូចដែលអ្នកមានបទពិសោធន៍នៃសេចក្តីសង្ឃឹមរបស់អ្នកចំពោះព្រះគ្រីស្ទ និង ឆ្លើយតបទៅចំពោះទ្រង់ជាមួយនឹងដួងចិត្តនៃការថ្វាយបង្គំ។

# តំណក់ទឹកភ្នែកប្រែទៅជាបេះដូង



